

## ជំពូកទី៨

# ការរៀនប្រើភាសាសញ្ញា

កុមារតូចងាយស្រួលរៀនភាសាសញ្ញាពេញលេញមួយ ។ ដំបូងកុមារចាប់ផ្តើមយល់សញ្ញាដែលប្រើដោយមនុស្សផ្សេងទៀត ជាពិសេសសញ្ញាសំរាប់សំគាល់មនុស្ស និងវត្ថុដែលកុមារឃើញរាល់ថ្ងៃ ។ បន្ទាប់ពីកុមារចាប់ផ្តើមប្រើសញ្ញាដែលសំខាន់ចំពោះខ្លួនឯង នោះកុមារនឹងរៀន ហើយប្រើសញ្ញាផ្សេងៗជាច្រើនទៀត ។

សញ្ញានីមួយៗជួយឱ្យកុមាររៀនពីពិភពលោកជុំវិញខ្លួនបានច្រើនថែមទៀត ។ កុមារផ្តើមរៀនផ្គុំសញ្ញាចូលគ្នា ខណៈដែលបំណិនភាសារបស់ខ្លួនបានអភិវឌ្ឍ ។ មួយរយៈក្រោយមក កុមារនឹងមានលទ្ធភាពធ្វើសញ្ញាជាប្រយោគពេញលេញ ។ **ប្រការនេះ ក៏ជួយអភិវឌ្ឍចិត្តគំនិតរបស់កុមារផងដែរ ។** អ្នកនឹងបានលទ្ធផលល្អ បើសិនជាអ្នក និងកូនរីករាយពេលរៀនភាសាជាមួយគ្នា ។




វិធីល្អបំផុតដែលអ្នក និងកូនរៀនភាសាសញ្ញាដែលប្រើក្នុងស្រុកភូមិ គឺត្រូវមានមនុស្សថ្លង់ពេញវ័យដែលប្រើភាសាសញ្ញានោះ ជួយបង្រៀនអ្នក ។ គោលការណ៍ណែនាំសំរាប់ការបង្រៀនភាសាដល់កូនអ្នក សូមអានជំពូកទី3 ។ ព័ត៌មានបន្ថែមអំពីរបៀបដែលមនុស្សថ្លង់ពេញវ័យអាចជួយបង្រៀនភាសាសញ្ញាដល់សហគមន៍ សូមអានទំព័រ130 និង150 ។ បើសិនជាគ្មាននរណាម្នាក់ជួយបង្រៀនភាសាសញ្ញា ប្រហែលជាមានសៀវភៅខ្លះៗដែលអ្នកអាចរៀនសញ្ញាមួយចំនួនដើម្បីប្រើជាមួយកូន ។ ប៉ុន្តែការរៀនភាសាសញ្ញាពីសៀវភៅ គឺពិបាកហើយមិនសូវមានប្រសិទ្ធភាពដូចរៀនពីបុគ្គលម្នាក់ឡើយ ។

ក្នុងជំពូកនេះ យើងបង្ហាញមនុស្សកំពុងប្រើសញ្ញា ហើយយើងក៏បានបង្ហាញពីរបៀបដែលអាចផ្គុំសញ្ញាចូលគ្នាផងដែរ ដើម្បីបង្កើត**សញ្ញាជាប្រយោគ** ឧទាហរណ៍ដូចនេះ :-

**រូបភាពតែមួយគត់ មិនបង្ហាញសញ្ញា ក្នុងល្បះមួយនោះទេ ។**







**ជូនកាលយើងបង្ហាញ សញ្ញាដែលជាល្បះ មួយក្នុងប្រអប់ដែល អ្នកអាចអានពីលើចុះក្រោម ។**

## ▶ របៀបជួយកុមារឱ្យយល់សញ្ញាថ្មីៗ

ដំបូងកុមាររៀនសញ្ញាសំរាប់មនុស្ស និងវត្ថុដែលសំខាន់ៗចំពោះខ្លួន។ ដូច្នេះចូរសំគាល់មើលថា របស់អ្វី និងអ្នកណាដែលកូនចាប់អារម្មណ៍។ ដើម្បីជួយកូនរៀនធ្វើសញ្ញាដំបូង :-

1. ជួយធ្វើសញ្ញានៅក្បែរវត្ថុ ឬចង្អុលទៅមនុស្ស ធ្វើដូច្នេះកូនអាចភ្ជាប់វាទាំងពីរចូលគ្នា។ បង្ហាញកូនថាមានអ្វីមួយសំខាន់នឹងកើតឡើងតាមរយៈទឹកមុខរបស់អ្នក។







2. ចូរធ្វើសញ្ញានៃវត្ថុ ឬមនុស្ស និងប្រើវាដដែលៗឡើងវិញ។ ត្រូវធ្វើឱ្យប្រាកដថា កូនឃើញមុខនិងដៃរបស់អ្នក នៅពេលអ្នកធ្វើសញ្ញាជាមួយកូន។




3. ចូរសំគាល់មើលការឆ្លើយតបរបស់កូន។ តើកូនឆ្លើយតបតាមរបៀបដែលគេបានយល់ន័យឬទេ? សរសើរកូន បើសិនជាដូច្នេះមែន។ បើសិនជាកូនមិនឆ្លើយតប ចូរធ្វើសញ្ញាឡើងវិញពីរបីដងទៀត។

4. ប្រើសញ្ញាទាំងនេះរៀងរាល់ថ្ងៃឱ្យបានច្រើនដងតាមដែលអាចធ្វើបាន។ លើកទឹកចិត្តគ្រួសារទាំងមូលឱ្យប្រើសញ្ញាទាំងនេះផងដែរ។ ចូរព្យាយាមអត់ធ្មត់។ កូនអាចចំណាយពេលមួយរយៈដើម្បីរៀនសញ្ញាដំបូងរបស់ខ្លួន។



## របៀបជួយកុមារឱ្យរៀនប្រភេទសញ្ញាខុសគ្នាៗ

កុមារត្រូវការរៀនសញ្ញាជាច្រើនប្រភេទខុសៗគ្នា បន្ថែមពីលើសញ្ញាសំរាប់មនុស្ស និងវត្ថុ។ ប្រការនេះជួយកុមាររៀនពីព្រឹត្តិការណ៍ទាំងឡាយដែលនៅជុំវិញខ្លួនបានច្រើនថែមទៀត។ វាក៏ជួយត្រៀមបំរុងកុមារឱ្យចេះគិត និងចេះធ្វើសញ្ញាជាល្បះនាពេលខាងមុខផងដែរ។

អ្នកអាចប្រើជំហានដូចគ្នានៅទំព័រមុន ដើម្បីបង្រៀនកូន "សញ្ញានៃ**សកម្មភាព**" "សញ្ញានៃ**អារម្មណ៏**" និង "សញ្ញានៃ**ការពិពណ៌នា**"។

- សញ្ញានៃសកម្មភាព

**សញ្ញាសំរាប់ហូប ផឹក និងដេក ជាញឹកញាប់គឺជាសញ្ញានៃសកម្មភាព ដែលកុមារតែងរៀនមុនគេបង្អស់។**







- សញ្ញានៃអារម្មណ៏

**សញ្ញាសំរាប់សប្បាយ ខឹង និងទុក្ខព្រួយ ជាញឹកញាប់គឺជាសញ្ញានៃអារម្មណ៏ដែលកុមារតែងរៀនមុនគេបង្អស់។**




- សញ្ញានៃការពិពណ៌នា

**សញ្ញាសំរាប់ស្ងួត សើម ក្តៅ និងត្រជាក់ ជាញឹកញាប់គឺជាសញ្ញានៃការពិពណ៌នា ដែលកុមារតែងរៀនមុនគេបង្អស់។**






ប្រភេទសញ្ញាសំខាន់ដទៃទៀតដែលត្រូវដឹងគឺ :-

- **សញ្ញាឈ្មោះ** ( ឈ្មោះដាក់ឱ្យបុគ្គលម្នាក់ៗ)







អ្នកអាចប្រឌិតសញ្ញាឈ្មោះសំរាប់មនុស្សម្នាក់ៗក្នុងផ្ទះ ។ វាងាយចាំសញ្ញានោះណាស់ បើសិនជាឈ្មោះនោះមើលទៅមានចំណុចខ្លះដូចរាងរៅរបស់បុគ្គលនោះ ។ បងប្អូនទាំងពីនាក់នេះ បានប្រឌិតឈ្មោះដាក់ឱ្យគ្នាទៅវិញទៅមក ដោយផ្អែកលើរូបសម្បត្តិរបស់ពួកគេ ។

***អុីសាបែល*** មាន
សក់រួញលើថ្ងាស ។





***កាឡូស*** មាន
ប្រជ្រុយលើថ្ពាល់ ។






## រៀនធ្វើសញ្ញា

កុមារចាប់ផ្តើមរៀនប្រើសញ្ញាដោយខ្លួនឯង ពេលពួកគេឃើញមនុស្សជុំវិញខ្លួនប្រើសញ្ញាដើម្បីប្រាស្រ័យទាក់ទង។ ត្រូវចាំថាសញ្ញាមួយចំនួនងាយស្រួលប្រើជាងសញ្ញាមួយចំនួនទៀត។



ទម្រង់ដៃបែបនេះ
គឺងាយស្រួលបត់ជាង។



ទម្រង់ដៃបែបនេះ
គឺពិបាកបត់ជាង។

ដំបូងកុមាររៀនកំណត់ទីតាំងដៃ នៅពេលពួកគេរៀនធ្វើសញ្ញា។ បន្ទាប់មកកុមាររៀនរំកិលដៃតាមទិសដៅ ហើយទីបញ្ចប់កុមាររៀនបត់ទម្រង់ដៃ និងម្រាមដៃឱ្យបានត្រឹមត្រូវ។

កូនអ្នកមិនអាចធ្វើសញ្ញានីមួយៗឱ្យត្រូវតាមក្បួនខ្នាតនោះទេ។ នៅពេលរៀនដំបូង អ្នកពិតជាមើលមិនយល់សញ្ញារបស់កូនឡើយ តែត្រូវសរសើរកូនដែលខិតខំធ្វើសញ្ញា និងមិនត្រូវមានកង្វល់ពីរឿងកូនធ្វើសញ្ញាឱ្យច្បាស់ៗនោះទេ។

### ▶ វិធីលើកទឹកចិត្តកូនឱ្យចាប់ផ្តើមប្រើសញ្ញា

1. សង្កេតមើលសារដែលកុមារធ្វើតាមរយៈកាយវិការ សម្លេង **និងការបញ្ចេញទឹកមុខ**។



2. ផ្តល់សញ្ញាសំរាប់សារដែលកុមារបានធ្វើទៅឱ្យក្មេង។




3. បញ្ជាក់សញ្ញាឡើងវិញ និងធ្វើដដែលៗឱ្យច្រើនដង។ លើកទឹកចិត្តកុមារឱ្យធ្វើត្រាប់តាមអ្នក។ សរសើរកុមារ បើសិនជាក្មេងព្យាយាមធ្វើត្រាប់តាមអ្នក។ កុំកែតម្រូវក្មេង បើសិនជាក្មេងមិនធ្វើសញ្ញាតាមវិធីត្រឹមត្រូវ។ អ្នកធ្វើសញ្ញាត្រឹមត្រូវនោះឡើងវិញជំនួសការកែតម្រូវកុមារ។




4. លើកទឹកចិត្តកុមារឱ្យប្រើសញ្ញាបានញឹកញាប់។ ពេលក្មេងរៀនចេះសញ្ញាហើយ រិះរកវិធីបញ្ចូលសញ្ញាទៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក។



សួរសំណួរដែលអាចឆ្លើយនឹងសញ្ញាទោល ។










និយាយសរសើរ បើសិនជាកុមារឆ្លើយតប ។ បើកុមារមិនឆ្លើយ :-

- កុមារប្រហែលមិនយល់សញ្ញា ។
- កុមារប្រហែលមិនយល់គំនិតនៃសំណួរដែលតម្រូវឱ្យឆ្លើយ ។

ដើម្បីបង្រៀនកុមារអំពីសំណួរតាមវិធីមួយ មុនដំបូងត្រូវឆ្លើយសំណួរជំនួសក្មេងសិន ។ មួយរយៈក្រោយមកកុមារពិតជាយល់ន័យពីគំនិតនោះ ។






## ▶ របៀបលើកទឹកចិត្តកុមារឱ្យចេះប្រាស្រ័យទាក់ទងនូវតម្រូវការសាមញ្ញៗ

ពេលកុមារចង់បានអ្វីមួយ គឺកុមារមានចិត្តចង់រៀនជាខ្លាំង កុមារដឹងថាសញ្ញានោះជួយបំពេញតម្រូវការរបស់ខ្លួន។ នេះជាគំនិតខ្លះៗសំរាប់ជួយលើកទឹកចិត្តកុមារឱ្យចេះប្រាស្រ័យទាក់ទងនូវតម្រូវការសាមញ្ញៗ :-




- លើកទឹកចិត្តកុមារឱ្យធ្វើសញ្ញាសំរាប់របស់ដែលគេចង់បាន នៅពេលណាដែលកុមារហាក់ដូចជាចង់បានអ្វីមួយ។
- បង្កើតស្ថានភាព ដែលធ្វើឱ្យកុមារត្រូវតែសួររករបស់អ្វីមួយ។




**ឪពុករបស់*អូស្កា* ឈប់លេងបាល់ ទាល់តែ*អូស្កា*សុំលេងបន្តទៀត។**

អ្នកធ្វើជាមិនយល់ ពេលកុមារប្រើកាយវិការដែលអាចមានន័យអ្វីផ្សេងទៀត។ លើកទឹកចិត្តកុមារឱ្យផ្ញើសារច្បាស់លាស់ដោយឱ្យកុមារធ្វើសញ្ញាមករកអ្នក។






## ▶ របៀបជួយកុមារឱ្យចេះធ្វើតាមសំណើសាមញ្ញៗ

កុមារអាចចាប់ផ្ដើមយល់សំណើសាមញ្ញដែលអ្នកស្នើឡើង ខណៈកុមារស្គាល់ឈ្មោះវត្ថុ មនុស្ស និងសកម្មភាព។ ចូរចាប់ផ្ដើមជាមួយសំណើខ្លីៗ។ បញ្ជាក់សញ្ញាដែលកុមារដឹងហើយ និងប្រើកាយវិការដើម្បីឱ្យសារនោះកាន់តែច្បាស់។ ត្រូវធ្វើយ៉ាងណាទុកពេលគ្រប់គ្រាន់ឱ្យកុមារឆ្លើយតប និងធ្វើតាមសំណើនោះ បើសិនជាចាំបាច់។

មុនដំបូងធ្វើសំណើអំពីវត្ថុ ឬមនុស្សដែលកុមារមើលឃើញជុំវិញខ្លួន។







បន្ទាប់មកធ្វើសំណើអំពីវត្ថុ ឬមនុស្សដែលកុមារមើលមិនឃើញដោយប្រើសញ្ញាដែលអ្នកបានបង្រៀនហើយ។



កុមារនឹងរៀនធ្វើសំណើដោយខ្លួនឯងយ៉ាងឆាប់រហ័ស ។ មនុស្សគ្រប់រូបគួរនាំគ្នាលើកទឹកចិត្តក្មេង ពេលក្មេងព្យាយាមធ្វើសំណើ ។




## ▶ របៀបជួយលើកទឹកចិត្តកុមារឱ្យរៀនសញ្ញាថែមទៀត

វិធីល្អបំផុតសំរាប់កុមាររៀនសញ្ញាបន្ថែមទៀត គឺត្រូវប្រាស្រ័យទាក់ទងជាមួយកុមារឱ្យបានច្រើនតាមដែលអាចធ្វើបាន និងលើកទឹកចិត្តឱ្យកុមារ**បញ្ជូនសារមកអ្នកវិញ** ។ **នេះជាគំនិតខ្លះៗ សំរាប់ការប្រាស្រ័យទាក់ទងនៅរាល់ពេលថ្ងៃ ។**

- សកម្មភាពប្រចាំថ្ងៃ គឺជាពេលល្អដើម្បីរៀនភាសាសញ្ញា ។ ក្នុងសកម្មភាពប្រចាំថ្ងៃ កុមារមានឱកាសប្រើសញ្ញាដដែលៗ ម្តងហើយម្តងទៀត ។




**ត្រូវធ្វើឱ្យប្រាកដថា កូនមើលមកអ្នក ពេលអ្នកធ្វើសញ្ញាជាមួយកូន ។**




- សូមអ្នកធ្វើជាខុស ដើម្បីលើកទឹកចិត្តឱ្យកូនកែតម្រូវអ្នកវិញ ។ ម្តាយក្មេងនេះ ធ្វើជាច្រឡំហៅឈ្មោះកូនប្រុសគាត់ ។



ចូរព្យាយាមប្រឌិតល្បែងលេង ដែលរួមមានសញ្ញាថ្មីខ្លះៗ។ ឧទាហរណ៍ :- កុមារទាំងនេះកំពុងលេងល្បែងលាក់វត្ថុដែលពួកគេអាចឱ្យឈ្មោះវាជាសញ្ញា។ ក្នុងពេលតែមួយ ពួកគេអាចរៀនសញ្ញាថ្មីខ្លះៗ។






## ការយល់ក្រុមសញ្ញា

ក្រោយពេលចេះសញ្ញាទោលហើយ កុមារចាប់ផ្តើមផ្គុំសញ្ញាចូលគ្នាដើម្បីសំដែងគំនិតពេញលេញ។ កុមារកំពុងស្ថិតលើផ្លូវឆ្ពោះទៅរកការប្រើភាសាមួយពេញលក្ខណៈ ដោយការរៀនផ្គុំសញ្ញាចូលគ្នាដើម្បីសំដែងគំនិតឱ្យបានពេញលេញ។

ការផ្គុំសញ្ញាចូលគ្នាជាក្រុម គឺជាជំហានដ៏ធំមួយសំរាប់កុមារ។ វាអនុញ្ញាតឱ្យកុមារប្រាស្រ័យទាក់ទងអំពីវត្ថុ និងមនុស្សជុំវិញខ្លួនបានច្រើនជាងឈ្មោះរបស់ពួកគេ។ ដំបូងកុមារដាក់សញ្ញាពីរចូលគ្នា។ បន្ទាប់មកកុមារចាប់ផ្តើមប្រើសញ្ញាបីចូលគ្នា និងទីបំផុតកុមារអាចប្រើក្រុមសញ្ញាវែងៗដែលមានច្រើនសញ្ញាចូលគ្នា។ ដំបូងកុមារត្រូវតែយល់របៀបដែលមនុស្សឯទៀតប្រើក្រុមសញ្ញានោះ មុនពេលកុមារអាចធ្វើបានដោយខ្លួនឯង។

## ▶ របៀបជួយកុមារឱ្យយល់ក្រុមសញ្ញា

1. នៅពេលកុមារហៅឈ្មោះមនុស្ស ឬវត្ថុ ចូរអ្នកពង្រីកពាក្យដែលកុមារបាននិយាយ ។




បញ្ជាក់ក្រុមសញ្ញាដែលអ្នកចង់ឱ្យកុមាររៀន និងធ្វើវាដដែលៗឡើងវិញ ។




2. សង្កេតមើលការឆ្លើយតបរបស់កូន ។ តើកូនឆ្លើយតបតាមរបៀបដែលបង្ហាញថាបានយល់ន័យឬទេ? បើដូច្នេះមែន ត្រូវសរសើរក្មេង ។ បើសិនជាកុមារមិនឆ្លើយតប ធ្វើសញ្ញាដដែលៗឡើងវិញ ។




3. ប្រើសញ្ញាទាំងនេះរាល់ពេលថ្ងៃឱ្យញឹកញាប់តាមដែលអាចធ្វើបាន ។ លើកទឹកចិត្តគ្រួសារទាំងមូលឱ្យប្រើសញ្ញាទាំងនេះផងដែរ ។




ក្នុងឧទាហរណ៍នេះ ឪពុកម្ដាយផ្គុំចូលគ្នានូវឈ្មោះវត្ថុ "ដើមឈើ" ជាមួយពាក្យដែលពិពណ៌នាវា "ធំ" ។



ការចេះពាក្យ និងចេះប្រើភាសាមួយជួយអភិវឌ្ឍចិត្តគំនិតរបស់កុមារ។ នៅពេលកុមារចេះពាក្យ "ធំ" និង "តូច" កុមារអាចប្រើពាក្យទាំងនោះ ដើម្បីគិតនិងបញ្ចេញគំនិតដែលពិបាកៗដូចជា ការប្រៀបធៀបរបស់មួយទៅរបស់មួយទៀត។ សូមអានជំពូកទី7 សំរាប់ព័ត៌មានអំពីរបៀបដែលភាសាជួយអភិវឌ្ឍចិត្តគំនិតរបស់កុមារ។

ដើម្បីបង្រៀនក្រុមសញ្ញាផ្សេងទៀតដល់កុមារ ចូរព្យាយាមផ្គុំឈ្មោះវត្ថុ ឬបុគ្គលចូលគ្នាជាមួយ :-

- ពាក្យ ឬសញ្ញាដែលបង្ហាញពីវត្ថុ ឬមនុស្សធ្វើអ្វីមួយ។










- ពាក្យ ឬសញ្ញាដែលបង្ហាញពី កន្លែងរបស់វត្ថុ ឬមនុស្ស។




- ពាក្យ ឬសញ្ញាដែលបង្ហាញថា ចង់បានអ្វីមួយថែមទៀត ឬចង់ឱ្យអ្វីមួយកើតឡើងម្តងទៀត។










- ពាក្យ ឬសញ្ញាដែលបង្ហាញថា មិនចង់បាន អ្វីមួយ អ្វីមួយអស់រលីង ឬអ្វីមួយដែល មិនអាចធ្វើកើត។



## ការប្រើប្រាស់ក្រុមសញ្ញា

កន្លងមកអ្នកបានប្រើក្រុមសញ្ញាដើម្បីប្រាស្រ័យទាក់ទងជាមួយកុមារ ។ ដើម្បីអាចឱ្យកុមារម្នាក់ចាប់ផ្ដើមប្រើក្រុមសញ្ញាបានដោយខ្លួនឯង កុមារត្រូវការចេះសញ្ញាខ្លះទៀត ដូច្នេះទើបកុមារអាចផ្គុំសញ្ញាចូលគ្នាតាមវិធីប្លែកៗ ។

### ▶ វិធីលើកទឹកចិត្តកុមារឱ្យចេះផ្គុំសញ្ញាចូលគ្នា

នៅពេលកុមារធ្វើសញ្ញាទោលមួយ លើកទឹកចិត្តកុមារឱ្យពង្រីកអ្វីដែលគេបាននិយាយ ។ អ្នកគួរ :-

- ពង្រីកសញ្ញាដោយខ្លួនឯង និងលើកទឹកចិត្តកុមារឱ្យធ្វើសញ្ញាតាមអ្នក ។




- សួរសំណួរ និងលើកទឹកចិត្តឱ្យក្មេងឆ្លើយ ។




- សួរកូនអំពីអ្វីមួយ ដែលកូនកំពុងធ្វើ ។









នេះជាវិធីខ្លះៗទៀត ដើម្បីលើកទឹកចិត្តកុមារឱ្យប្រើក្រុមសញ្ញា :-

- ប្រើកូនឱ្យនាំសារធម្មតាមួយទៅនរណាម្នាក់ ។




- ព្យាយាមនិយាយរឿងជាមួយគ្នា ។ ពេលកុមារឃើញអ្នកនិយាយរឿងមួយច្រើនដង កុមារអាចមានលទ្ធភាពនិទានរឿងជាសញ្ញាបានមួយចំណែកដោយខ្លួនឯង ។




- លើកទឹកចិត្តកូនឱ្យដើរតួប្លែកៗពីគ្នា ។






## ▶ ប្រើសំណួរដើម្បីលើកទឹកចិត្តកុមារឱ្យចេះគិត

ការសួរសំណួរជាវិធីល្អមួយ ដើម្បីបន្តការប្រាស្រ័យទាក់ទង ។ សំណួរក៏ជួយលើកទឹកចិត្តកុមារឱ្យចេះគិតផងដែរ ។

- សួរឱ្យកូនចេះគិតតាមវិធីថ្មី ដោយឱ្យកិច្ចការកូនធ្វើ ។ បន្ទាប់មក លើកទឹកចិត្តកូនឱ្យប្រាស្រ័យទាក់ទងអំពីអ្វីដែលកូនកំពុងធ្វើ ។







- នៅពេលកុមារមានបញ្ហាឱ្យកូនប្រាប់អ្នកថាត្រូវដោះស្រាយបែបណា ។






- នៅពេលអ្នកសំគាល់ឃើញថា កូនសំដែងអារម្មណ៍រំជួលចិត្ត ឱ្យកូនប្រាប់អ្នកពីអារម្មណ៍ក្នុងចិត្តរបស់គេ។

បើកូនមានបញ្ហាលំបាកឆ្លើយតបទៅអ្នក ដំបូងត្រូវគិតថាតើកូនចេះសញ្ញាដែលត្រូវឆ្លើយនឹងសំណួរឬទេ។ បើកូនមិនចេះ សូមជួយកូនឱ្យរៀនសញ្ញាទាំងនោះ។




សំណួរ "ហេតុអ្វី" អាចជាការស្មុគស្មាញ និងពិបាកសំរាប់កុមារឆ្លើយ។ ពីព្រោះចម្លើយទៅនឹងសំណួរ "ហេតុអ្វី" ច្រើនតែរួមបញ្ចូលទាំងវត្ថុ ទាំងសកម្មភាព និងអារម្មណ៍រំជួលចិត្តដែលសំខាន់សំរាប់អភិវឌ្ឍបំណិនការគិតរបស់ក្មេង។ កុមារត្រូវការហាត់រៀនឱ្យបានច្រើនដើម្បីឆ្លើយសំណួរទាំងនេះ ដូច្នេះត្រូវបន្តអនុវត្តជាមួយសំណួរ "ហេតុអ្វី?"។ បើសិនជាកូនអ្នកនៅតែពិបាកឆ្លើយសំណួរ ចូរផ្ដល់ជម្រើសមួយចំនួនឱ្យកុមារ។



## ▶ របៀបជួយកុមារឱ្យធ្វើតាមសំណើពីរជំហាន

នៅពេលកុមារបានយល់សញ្ញាជាច្រើនហើយ នោះកុមារអាចចាប់ផ្តើមធ្វើតាមសំណើដែលពិបាកៗ។ អ្នកអាចចាប់ផ្តើមពង្រីកសំណើសាមញ្ញដែលកុមារបានយល់ហើយ ដោយសម្រួលវាទៅជាសំណើពីរជំហាន។

ដំបូង ធ្វើសំណើអ្វីមួយដែលកុមារអាចមើលឃើញ។





លាងដៃ


ហូប

បន្ទាប់មក ធ្វើសំណើឱ្យពិបាកបន្តិចម្តងៗ។




## ▶ ជួយកុមារឱ្យចេះសំគាល់ថា របៀបធ្វើសញ្ញាមួយ គឺជាចំណែកមួយនៃន័យរបស់វា

មនុស្សម្នាក់បន្ថែមន័យទៅសញ្ញារបស់ខ្លួន ដោយធ្វើឱ្យសញ្ញានោះរីកធំ ឬបង្រួមឱ្យតូចដោយធ្វើសញ្ញានោះឱ្យលឿន ឬឱ្យយឺតជាងសញ្ញាដទៃទៀត តាមរយៈការផ្លាស់ប្តូរទឹកមុខ។

ជួយកុមារឱ្យផ្តោតការយកចិត្តទុកដាក់លើវិធីខុសប្លែកគ្នាទាំងនេះ ធ្វើដូច្នេះកុមារអាចយល់សារដែលបញ្ជូនមកបានកាន់តែច្រើន ។

**បើសិនជាអ្នកចង់និយាយ អ្វីមួយអាក្រក់ អ្នកអាចធ្វើ សញ្ញាដូចនេះ។**


អាក្រក់

**បើសិនជាអ្នកចង់និយាយថា វាអាក្រក់ណាស់ អ្នកធ្វើ សញ្ញាដូចគ្នា "អាក្រក់" ឱ្យធំ និងឱ្យលឿនជាងមុន។**


អាក្រក់ណាស់

ការនិទានរឿងប្រាប់កុមារ គឺជាវិធីរីករាយបំផុតដើម្បីបង្រៀនភាសាសញ្ញាដល់កុមារ។ ព្យាយាមធ្វើសញ្ញាតាមបែបផ្សេងៗគ្នា ពេលអ្នកសំដែងតួជាមនុស្សខុសៗគ្នា។ ចូរព្យាយាមសំដែងអារម្មណ៍រំជួលចិត្តឱ្យបានច្រើនផងដែរ (ដូចជារីករាយ និងតូចចិត្តណាស់) ត្រូវបង្ហាញរបៀបដែលតួអង្គនីមួយៗមានអារម្មណ៍យ៉ាងណាខ្លះ តាមរយៈសម្លេងនិយាយរបស់អ្នក និងនៅលើទឹកមុខរបស់អ្នក។







**សញ្ញា “ឪពុកខ្លាឃ្មុំ”**







**សញ្ញា “កូនខ្លាឃ្មុំ”**

ការធ្វើសញ្ញាសំរាប់តួអង្គមនុស្សខុសៗគ្នា ជួយកុមារឱ្យផ្តោតការយកចិត្តទុកដាក់ទៅលើសាច់រឿង។ វាក៏ជួយកុមារឱ្យមើលឃើញការសំដែងអារម្មណ៍ ទំហំ និងការធ្វើសញ្ញាតាមវិធីប្លែកៗគ្នា។

## ការបង្រៀនភាសាសញ្ញាដល់ឪពុកម្ដាយរបស់កុមារថ្លង់

មនុស្សដែលប្រើភាសាសញ្ញាជាភាសាកំណើតរបស់ខ្លួន អាចជួយបង្រៀនឪពុកម្ដាយពីរបៀបប្រាស្រ័យទាក់ទងជាមួយទារក ឬកុមារថ្លង់។

នេះជារឿងមួយស្ដីអំពីក្រុមរបស់ម្ដាយនៃកុមារថ្លង់ជនជាតិឥណ្ឌាដែលរស់នៅប្រទេសអង់គ្លេស ដែលពួកគេបានរៀនភាសាសញ្ញាអង់គ្លេសពីគ្រូបង្រៀនម្នាក់ដែលជាមនុស្សថ្លង់។ មុនពេលពួកគេរៀនភាសាសញ្ញា កុមារនិងឪពុកម្ដាយរបស់ពួកគេមានបញ្ហាក្នុងការប្រាស្រ័យទាក់ទងគ្នា ដោយសារតែពួកគេពិបាកយល់គ្នាខ្លាំងពេក។ ការរៀនភាសាសញ្ញាបានធ្វើឱ្យប្រែប្រួលបែបនេះ។

### ការធ្វើសញ្ញាឆ្លងកាត់របាំងភាសា

លីស្សាជាស្ត្រីអង់គ្លេស ដែលថ្លង់ពីកំណើត។ ក្រោយពេលនាងបញ្ចប់ការសិក្សានៅសាលាគរុកោសល្យ នាងមានការងារជាគ្រូបង្រៀនកុមារថ្លង់។ ការងារមួយចំណែករបស់នាង គឺជួយម្ដាយកុមារថ្លង់ឱ្យរៀនភាសាសញ្ញា។ ក្រុមមួយក្នុងចំណោមក្រុមទាំងឡាយដែលលីស្សាបង្រៀន គឺក្រុមស្ត្រីឥណ្ឌាដែលមិនចេះនិយាយភាសាអង់គ្លេស។ ដំបូងលីស្សា និងក្រុមស្ត្រីឥណ្ឌាមានការពិបាកប្រាស្រ័យទាក់ទងគ្នា។ លីស្សាប្រើភាសាសញ្ញាអង់គ្លេស និងគ្រូបង្រៀនម្នាក់ទៀតជួយបកប្រែជាភាសានិយាយអង់គ្លេស។ បន្ទាប់មកមាននារីម្នាក់ទៀត បកប្រែពីភាសានិយាយអង់គ្លេសទៅជាភាសា***ពុនចាប៊ី*** ដែលជាភាសាកំណើតរបស់ស្ត្រីឥណ្ឌាទាំងនោះ។

ដំបូងក្រុមម្ដាយទាំងនោះបានរៀនសញ្ញាអំពីផ្ទះសម្បែង។ ពួកគេក៏បានរៀនសញ្ញាទាំងឡាយដែលកូនៗបានរៀននៅក្នុងថ្នាក់រៀនផងដែរ។ ប្រការនេះជួយឱ្យឪពុកម្ដាយបានយល់ និងបានប្រាស្រ័យទាក់ទងជាមួយកូនៗនៅឯផ្ទះ។




ក្រោយមកទៀត បុរសម្នាក់បានចូលរួមក្នុងក្រុមម្ដាយរៀនសញ្ញារបស់លីស្សា។ បន្ទាប់មកបុរសនោះបានជួយបង្រៀនឪពុក និងបងប្រុសក្នុងក្រុមសំរាប់បុរស។ នៅក្នុងក្រុមទាំងពីរ ឪពុកម្ដាយរបស់កុមារថ្លង់ធំៗបានចែករំលែកបទពិសោធន៍ដល់ឪពុកម្ដាយរបស់កុមារថ្លង់តូចៗ។ ប្រការនេះអនុញ្ញាតឱ្យពួកគេប្រើបំណិនភាសាសញ្ញាថ្មី ដើម្បីនិយាយអំពីអ្វីដែលសំខាន់ៗចំពោះពួកគេ។

ដោយសង្កេតមើលការងារ និងការបង្រៀនរបស់លីស្សា ឪពុកម្ដាយបានឃើញថា កុមារថ្លង់អាចក្លាយជាគ្រូបង្រៀន ចិញ្ចឹមជីវិតខ្លួនឯង និងបានការគោរពពីមនុស្សទាំងឡាយ។ ទន្ទឹមនឹងរៀនរបៀបប្រាស្រ័យទាក់ទងជាមួយកូនថ្លង់ ក្រុមគ្រួសារជាច្រើននៅក្នុងសហគមន៍ ក៏បានរៀនអ្វីមួយអំពីមនុស្សថ្លង់ផងដែរ។

## គន្លឹះជួយឱ្យមនុស្សធំរៀនភាសាសញ្ញា

ភាសាសញ្ញាពឹងផ្អែកយ៉ាងច្រើនលើការសំដែងអ្វីៗតាមរយៈរាងកាយទាំងមូល ។ របៀបឈរ និងការសំដែងទឹកមុខទាំងអស់ត្រូវការប្រាស្រ័យទាក់ទងឱ្យបានច្រើនដូចដៃរបស់អ្នកអញ្ចឹងដែរ ។

**ឧទាហរណ៍ :- សូមមើលរបៀបដែល *ទីម៉ី* ផ្លាស់ប្តូរការសំដែងកាយវិការលើរាងកាយទាំងមូល**
**ពេលនាងសួរសំណួរ " តើយើងគួរធ្វើយ៉ាងណា?" ជាភាសាសញ្ញា ។**




មនុស្សថ្លង់មើលមុខបុគ្គលដែលពួកគេកំពុងប្រាស្រ័យទាក់ទងជាមួយ មិនត្រឹមតែមើលដៃបុគ្គលនោះប៉ុណ្ណោះទេ គឺដូចគ្នានឹងមនុស្សស្តាប់ឮមើលមុខគ្នាទៅវិញទៅមក នៅពេលពួកគេស្តាប់គ្នាអញ្ចឹងដែរ ។

- សំដែងតួនូវអ្វីៗដែលអ្នកចង់និយាយ ។ កុំបារម្ភពីរឿងធ្វើខុស ឬក៏ខ្លាចគេមើលមកមិនសមរម្យ ។
- ប្រើអ្វីក៏ដោយ និងប្រើអ្វីៗទាំងអស់ដែលជួយដល់ការប្រាស្រ័យទាក់ទង :- កាយវិការ ផ្លាស់ប្តូរទឹកមុខ ចលនារាងកាយ ការចង្អុល ការធ្វើសញ្ញា និងប្រើម្រាមដៃប្រកបតួអក្សរ ( ប្រកបពាក្យដោយការប្រើសញ្ញាសំរាប់តួអក្សរនីមួយៗ ) ។ ព្យាយាមប្រាស្រ័យទាក់ទងជាមួយគំនិត ឬល្បះសាមញ្ញដោយគ្មានសញ្ញាផ្លូវការអ្វីទាំងអស់ ។ ចូរប្រើតែកាយវិការ សំដែងទឹកមុខ និងការចង្អុល ។ ទោះបីជាអ្នកមិនចេះសញ្ញា ឬភ្លេចសញ្ញាផ្លូវការក៏ដោយ ក៏អ្នកអាចប្រាស្រ័យទាក់ទងបែបនេះជាមួយមនុស្សថ្លង់ ។
- មនុស្សម្នាក់ៗរៀនភាសាតាមវិធីផ្សេងៗគ្នា និងតាមល្បឿនខុសៗគ្នា ។ ចូរខិតខំរៀនឱ្យបានច្រើនតាមតែអ្នកអាចធ្វើបាន ។ កុំព្រួយបារម្ភរឿងមនុស្សផ្សេងទៀតបានរៀនហើយ ឬមិនទាន់រៀន ។ គោលបំណងរបស់អ្នកគឺជួយកូនឱ្យរៀនសូត្រ មិនមែនសំរាប់ប្រជែងជាមួយមនុស្សឯទៀតឡើយ ។
- ដើម្បីរៀនភាសាសញ្ញាឱ្យបានជ្រៅជ្រះ ប្រើវាឱ្យបានញឹកញាប់ជាមួយមនុស្សថ្លង់ដែលចេះសញ្ញានោះ ។




ការរៀនភាសាសញ្ញាមិនមែនជាការងាយស្រួលនោះទេ ។ តែសូមចាំទុកថា វាសំខាន់ចំពោះកូនដែលមានភាសារួមគ្នាមួយសំរាប់ចែករំលែកជាមួយអ្នកទាំងអស់គ្នា ។ ចូរបន្តអនុវត្តភាសាសញ្ញា បើសិនជាអ្នកមិនប្រើវា អ្នកនឹងបាត់បង់វា គឺដូចគ្នានឹងភាសាដទៃទៀតដែលអ្នកចេះអញ្ចឹងដែរ ។